**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**
**រាជបណ្ឌិត្យសភាកម្ពុជា**

**Royal Academy of Cambodia**
**Académie Royale du Cambodge**

**គណៈកម្មាធិការលទ្ធកម្ម( គ.ល-PC )**
លេខ: ០១២ /២៤ ស.ជ.ណ

ថ្ងៃព្រហស្បតិ៍ ៥រោច ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២៤

# សេចក្តីជូនដំណឹង
## ស្តីពី
## ការអញ្ជើញចូលរួមដេញថ្លៃ ការផ្គត់ផ្គង់សម្ភារៈសង្ហារឹម និងសម្ភារៈអេឡិចត្រូនិច ឆ្នាំ២០២៤ សម្រាប់រាជបណ្ឌិត្យសភាកម្ពុជា

រាជបណ្ឌិត្យសភាកម្ពុជា សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យបានជ្រាបថា រាជបណ្ឌិត្យសភាកម្ពុជា នឹងដាក់ឱ្យដេញថ្លៃជាសាធារណៈ ការផ្គត់ផ្គង់សម្ភារៈសង្ហារឹម និងសម្ភារៈអេឡិចត្រូនិចឆ្នាំ២០២៤ សម្រាប់រាជបណ្ឌិត្យសភាកម្ពុជា។

រាជបណ្ឌិត្យសភាកម្ពុជា បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញ ដើម្បីចូលរួមដេញថ្លៃ និងមានដាក់លក់ នៅអង្គភាពលទ្ធកម្ម នៃរាជបណ្ឌិត្យសភាកម្ពុជា ដែលមានអាសយដ្ឋាននៅ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ (អគារខេមរវិទូ ជាន់ទី១) ចាប់ពីថ្ងៃទី ..០១..... ខែ..សីហា.. ឆ្នាំ២០២៤ រៀងរាល់ម៉ោងធ្វើការ ( ទូរសព្ទទាក់ទងលេខ: ០២៣ ៨៩០ ១៨០ )។

កាលបរិច្ឆេទឈប់ទទួល និងបើកសំណើដេញថ្លៃនឹងប្រព្រឹត្តទៅនៅ អង្គភាពលទ្ធកម្ម នៃរាជបណ្ឌិត្យសភាកម្ពុជា តាមកាលបរិច្ឆេទដូចខាងក្រោម៖

១ ) ការផ្គត់ផ្គង់សម្ភារៈសង្ហារឹម វេលាម៉ោង ១០:៣០ ព្រឹក ថ្ងៃទី ២៣... ខែ...សីហា..... ឆ្នាំ២០២៤
២ ) ការផ្គត់ផ្គង់សម្ភារៈអេឡិចត្រូនិច វេលាម៉ោង ១១:០០ ព្រឹក ថ្ងៃទី ..២៣... ខែ..សីហា ឆ្នាំ២០២៤

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយ អង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មានដែលទាក់ទងនឹងការដេញថ្លៃនេះ។

**ប្រធានគណៈកម្មាធិការលទ្ធកម្ម**
**និងជាប្រធានរាជបណ្ឌិត្យសភាកម្ពុជា**

បណ្ឌិតសភាចារ្យ **សុខ ទូច**

អាសយដ្ឋាន ៖ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ - ប្រអប់សំបុត្រលេខ៥៣១ ភ្នំពេញ កម្ពុជា
Tel/Fax: (855) 23 890 180, Website: www.rac.gov.kh, E-mail: info@rac.gov.kh, P.O.Box 531 Phnom Penh, Cambodia